Note: When this publication was originally published, we were known as Protection & Advocacy, Inc. (PAI).
In October 2008, we changed our name from PAI to Disability Rights California.

Cambodian

# **EEK!** កូនពិការរបស់ខ្ញុំ ឧស្សាហ៍ទទួលការបញ្ឈប់បណ្តោះអាសន្ន មិនឲ្យមករៀនញឹកញាប់ណាស់ !

## *តើខ្ញុំអាចធ្វើអ្វីបាន ?*
## *តើសិទ្ធិកូនរបស់ខ្ញុំមានអ្វីខ្លះ ?*




**Protection & Advocacy, Inc.**
3580 Wilshire Blvd., Suite #902
Los Angeles, CA 90010
ទូរស័ព្ទ 213.427.8747
ទូរសារ 213.427.8767
ប្រព័ន្ធ TTY 800.727.4546

"Advancing the human and legal rights of people with disabilities."

# **EEK!** កូនពិការរបស់ខ្ញុំ
# ឧស្សាហ៍ទទួលការបញ្ឈប់បណ្ដោះអាសន្នមិនឲ្យមករៀនញឹកញាប់ណាស់ !

# តើខ្ញុំអាចធ្វើអ្វីបាន ? តើសិទ្ធិកូនរបស់ខ្ញុំមានអ្វីខ្លះ ?

---

*"កូនប្រុសរបស់ខ្ញុំមានអកប្បកិរិយាមិនគប្បីដែលឧស្សាហ៍ធ្វើឲ្យវាមានបញ្ហានៅសាលារៀន ។ គ្រូបង្រៀនទាំងអស់របស់វាខឹងចម្បារចំពោះវា; គេតែងទូរស័ព្ទមកខ្ញុំ ឬបញ្ជូនកូនខ្ញុំទៅកាន់ការិយាល័យនាយកសាលារៀន, ហើយបានទទួលការបញ្ឈប់បណ្ដោះអាសន្នមិនឲ្យមករៀនជាច្រើនលើកនៅក្នុងឆ្នាំសិក្សានេះ ។ សាលារៀនឥឡូវនេះចង់ដកយកកូនខ្ញុំដាក់ឲ្យនៅរៀនក្នុងទីកន្លែងសិក្សាដែលមានកំរិតលក្ខខណ្ឌ ហើយគ្រូបង្រៀនទាំងអស់ក៏ជួនកាលនិយាយថា បើសិនជាកូនប្រុសរបស់ខ្ញុំនៅតែប្រព្រឹត្តបែបនេះតទៅទៀត, ពួកគាត់នឹងបណ្ដេញចេញ ឬដកចេញជាអចិន្ត្រៃយ៍ ។ ខ្ញុំមានការព្រួយខ្លាចចំពោះកូនខ្ញុំ ។"*

បើសិនជាសម្លេងបែបនេះ ដូចជាស្ថានភាពរបស់លោកអ្នកមាន ឬលោកអ្នកធ្លាប់មានការដកពិសោធន៍ប្រហាក់ប្រហែលនេះ, មានប្រការខ្លះដែលលោកអ្នកគួរដឹង ដើម្បីជួយដល់កូនរបស់លោកអ្នក ។

សូម្បីតែក្មេងទាំងឡាយមានភាពពិការជាទូទៅចាត់ទុកដូចជាក្មេងធម្មតាចំពោះរឿងទាក់ទងទៅនិងការបញ្ឈប់បណ្ដោះអាសន្នមិនឲ្យមករៀន, មានកំរិតខ្លះដល់របៀបណានិងពេលណាក្មេងសិក្សាអប់រំពិសេសប្រហែលជាបញ្ឈប់បណ្ដោះអាសន្នបាន ម្ដងចំនួននៃការបញ្ឈប់បណ្ដោះអាសន្នជាប់ៗគ្នា ឬបូកបញ្ចូលថ្ងៃទាំងអស់បានកើតឡើង ។ មិនតែប៉ុណ្ណោះ មានច្បាប់រដ្ឋនិងរដ្ឋាភិបាលទាំងឡាយលើការទប់រាំងអកប្បកិរិយាល្អ ដែលប្រហែលជាអាចជួយដល់កូនលោកអ្នករៀនបន្ថែមពីអកប្បកិរិយាឲ្យបានសមរម្យ ដើម្បីកាត់បន្ថយនូវភាពទំនងទទួលការបញ្ឈប់បណ្ដោះអាសន្នមិនឲ្យមករៀន ឬបណ្ដេញចេញពីសាលារៀន ។

ព្រឹត្តិប័ត្រនេះនឹងផ្តល់ឲ្យនូវគោលពត៌មានខ្លះៗទាក់ទងទៅនិងសិទ្ធិរបស់កូនលោកអ្នក បើសិនជាក្មេងប្រុសស្រីនោះគេកំពុងតែមានបញ្ហាពីអកប្បកិរិយា ហើយ/ឬការបញ្ឈប់បណ្តោះអាសន្នមិនឲ្យមករៀន ។

*អត្ថបទនៅក្នុងព្រឹត្តិប័ត្រនេះមាន :*

A. ការបញ្ឈប់បណ្តោះអាសន្ន
B. ការគាំទ្រអកប្បកិរិយាល្អ និងការធ្វើអន្តរាគមន៍
C. បរិវេណដែលមានកំរិតលក្ខខ័ណ្ឌតិច និងទីកន្លែងរៀនសូត្រ

*** បើសិនជាកូនគេកំពុងតែគិតបណ្តេញចេញ ឬតំបន់អប់រំបានហៅលោកអ្នកមកសំរាប់ធ្វើ "កំណត់ជាក់ស្តែង" ឬ "ភាពមានអាសន្ន" IEP ពីរឿងទាក់ទងទៅនិងអកប្បកិរិយារបស់កូនលោកអ្នក, សូមអញ្ជើញមើលព្រឹត្តិប័ត្ររបស់យើងស្តីពីការបណ្តេញចេញចំពោះក្មេងដែលត្រូវការសេចក្តីត្រូវការពិសេស, មានចំណងជើង *YIKES! កូនពិការរបស់ខ្ញុំគេកំពុងតែយកមកពិនិត្យដើម្បីបណ្តេញចេញ !* ***

## *A. ការបញ្ឈប់បណ្តោះអាសន្ន*

សិស្សដែលមានភាពពិការជាទូទៅទទួលពិន័យដូចសិស្សធម្មតាក្នុងករណីបញ្ឈប់បណ្តោះអាសន្ន[1] សូម្បីតែមានអកប្បកិរិយាមិនគប្បីដែលទាក់ទងផ្ទាល់ដល់ភាពពិការរបស់ពួកគេក៏ដោយ ។ ការខុសប្លែកគ្នាលើពិន័យរវាងក្មេងពិការនិងក្មេងធម្មតា គឺវាយោងទៅលើរយៈពេលបញ្ឈប់បណ្តោះអាសន្នមិនឲ្យមករៀន ហើយនិងចំនួនថ្ងៃបញ្ឈប់បណ្តោះអាសន្នដែលរាប់កើតឡើងក្នុងឆ្នាំសិក្សា ។ លើកលែងតែនៅក្នុងកាលៈទេសៈមានកំរិត, សិស្សធម្មតានៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ាអាចដាក់បញ្ឈប់បណ្តោះអាសន្នមិនមករៀនបានដល់ 20 ថ្ងៃត្រួតលើគ្នាក្នុងមួយឆ្នាំសិក្សា។ [2] ក៏ប៉ុន្តែ សិស្សដែលទទួលការអប់រំពិសេសជាទូទៅប្រហែលជាមិនអាចបញ្ឈប់បណ្តោះអាសន្ន ឬដកចេញលើសពី 10 ថ្ងៃសិក្សាជាប់ៗគ្នា[3]បានដោយគ្មានការយល់ព្រមពីមាតាបិតា ឬតុលាការ ឬបទបញ្ជាពីមន្ត្រីសវនាការ ។ ដោយមិនគិតពីកាលៈទេសៈ គួរសិស្សដែលទទួលការអប់រំពិសេសរារាំងមិនឲ្យទទួលកិច្ចបំរើសិក្សាបានសមរម្យហួសពី 10 ថ្ងៃសិក្សាផ្ទួនៗគ្នា ដោយគ្មានធ្វើឲ្យមានការកើតឡើងនូវការពិនិត្យមើលឡើងវិញពីកំណត់ជាក់ស្តែង ហើយនិងប្រការការពារច្បាប់បន្ថែមសំរាប់ឲ្យសិស្សដែលមានភាពពិការ ។ [4]

នៅពេលបញ្ឈប់បណ្តោះអាសន្ន, បុគ្គលិកសាលារៀន ឬតំបន់អប់រំមានអាជ្ញាធរដកសិស្សទទួលការអប់រំពិសេសចេញពីកន្លែងសិក្សាបច្ចុប្បន្នទៅដាក់កន្លែងសិក្សាផ្សេងទៀតជាបណ្តោះអាសន្នបាន, រឿងនេះជាញឹកញាប់ហៅថា "កន្លែងជំនួសបណ្តោះអាសន្ន" ។ ក៏ប៉ុន្តែ ការដកចេញមិនប្រព្រឹត្តទៅឲ្យហួសពី 10 ថ្ងៃសិក្សាផ្ទួនៗគ្នាបានទេ ។ [5] សិស្សទទួលការអប់រំពិសេសក៏អាចទទួលការបញ្ឈប់បណ្តោះអាសន្នជាច្រើនដងចំពោះទោសកម្មប្រព្រឹត្តខុសៗគ្នា ដែលបូកបញ្ចូល ឬរាប់បញ្ចូលលើសពី 10 ថ្ងៃសិក្សាក្នុងឆ្នាំសិក្សា, អោយតែមានការបញ្ឈប់បណ្តោះអាសន្នម្តងមិនហួសពី 10 ថ្ងៃសិក្សាជាប់ៗគ្នា ហើយរួមបញ្ចូលគ្នាវាមិនបង្កើតជាគំរូ ដែលអាចយកមកគិតធ្វើជាការផ្លាស់ប្តូរនៃទីកន្លែងសិក្សា ។ [6]

ក៏ប៉ុន្តែ, សិស្សដែលទទួលការអប់រំពិសេសត្រូវតែទទួលការអប់រំសាធារណៈមិនគិតថ្លៃបានសមរម្យ (FAPE) ក្រោយពីបានបញ្ឈប់បណ្តោះអាសន្នលើសពី 10 ថ្ងៃត្រួត

គ្នាក្នុងឆ្នាំសិក្សា សូម្បីបើការបបញ្ឈប់បណ្តោះអាសន្នកើតឡើងក្នុងទីកន្លែងសិក្សាជំនួសបណ្តោះអាសន្នក៏ដោយ ។ [7] តំបន់អប់រំត្រូវតែផ្តល់កិច្ចបំរើទាំងឡាយ, ដល់សេចក្តីចាំបាច់, ដើម្បីទុកពេលវេលាឲ្យសិស្សនោះកើនការរីកចំរើនសមរម្យតាមគំរោងសិក្សាទូទៅ ហើយនិងដើម្បីកើនរីកចំរើនឲ្យបានសម្រេចតាមគោលបំណង IEP របស់គេ ។ [8] នេះមានន័យថា នៅថ្ងៃទី 11 នៃថ្ងៃបញ្ឈប់បណ្តោះអាសន្នក្នុងឆ្នាំសិក្សា, តំបន់អប់រំត្រូវតែផ្តល់ដល់សិស្សដែលទទួលកម្មវិធី FAPE សូម្បីតែសិស្សនោះប្រហែលជាមិនមែននៅក្នុងទីកន្លែងសិក្សាបច្ចុប្បន្នរបស់វាក្នុងការទទួលកិច្ចបំរើអប់រំរបស់វាក៏ដោយ ។

ឧទាហរណ៍, បើសិនជាសិស្សទទួលការអប់រំពិសេសទទួលការបញ្ឈប់បណ្តោះអាសន្នដោយវាយតប់គ្នាក្នុងទីធ្លាសាលារៀន, ក្មេងនោះទទួលការបបញ្ឈប់បណ្តោះអាសន្នដល់ទៅ 10 ថ្ងៃម្តង ហើយរារាំងមិនឲ្យមកសាលារៀន ឬទោះបីជាបានបញ្ជូនទៅទីកន្លែងរៀនផ្សេងទៀតចំពោះរយៈពេលឈប់នោះក៏ដោយ ។ បន្ទាប់មកបើសិនជា 4 អាទិត្យក្រោយមក, សិស្សដដែលប្រព្រឹត្តឆាឆៅរំខាន ហើយស្រែកជេរពាក្យចំអាសមិនគប្បីដាក់គ្រូបង្រៀនរបស់ខ្លួន និងសិស្សដទៃ, ក្មេងនោះអាចទទួលការបញ្ឈប់បណ្តោះអាសន្នម្តងទៀតរហូតដល់ទៅ 10 ថ្ងៃសិក្សាបន្ថែមម្តងទៀត ។ ក៏ប៉ុន្តែ ពីព្រោះតែការបញ្ឈប់បណ្តោះអាសន្នលើកទីពីរប្រហែលជាសរុបទៅលើសពី 10 ថ្ងៃសិក្សាក្នុងឆ្នាំសិក្សា, តំបន់អប់រំត្រូវតែផ្តល់ឲ្យសិស្សនូវកម្មវិធី FAPE ក្នុងទីកន្លែងសិក្សាជំនួសបណ្តោះអាសន្ន ។ បើសិនជាសិស្សទទួលការបញ្ឈប់បណ្តោះអាសន្នដល់ទៅ 11 ថ្ងៃ ឬលើសពីនេះក្នុងឧប្បត្តិហេតុម្តងណាមួយ, បន្ទាប់មកការបញ្ឈប់បណ្តោះអាសន្នប្រហែលជាគិតតែម្តងថាជាគិតគូផ្លាស់ប្តូរទីកន្លែងសិក្សា, ហើយធ្វើឲ្យមានកើតការការពារតាមច្បាប់ពិសេសសំរាប់ឲ្យសិស្សទាំងឡាយនោះដែលមានភាពពិការ ដែលត្រូវគេកំពុងតែគិតគូបណ្តេញចេញ ។ [9] សិស្សានុសិស្សទាំងអស់ដែលមានភាពពិការ ឬមិនមាន គឺមានកំរិតសរុបតែ 20 ថ្ងៃនៃការបញ្ឈប់បណ្តោះអាសន្នក្នុងឆ្នាំសិក្សា (លើកលែងតែវាអាចទទួលច្រើនថ្ងៃដល់ទៅ 30 ថ្ងៃក្នុងឆ្នាំសិក្សាចំពោះសិស្សទាំងឡាយណាដែលកំពុងតែកែសម្របខ្លួនដល់ការបញ្ជូនទៅសាលារៀនថ្មី) ។ [10]

ចូរចាំថា នោះពីព្រោះតែតំបន់អប់រំប្រហែលជាបានចាប់ផ្តើមផ្តល់កិច្ចបំរើខ្លះក្នុងទីកន្លែងសិក្សាជំនួសបណ្តោះអាសន្នដែលជាផ្នែកនៃកាតព្វកិច្ចរបស់គេ ដើម្បីឲ្យកម្មវិធី FAPE

បានប្រាកដ, វាមិនមែនមានន័យថា តំបន់អប់រំលើកលែងពីកំណត់ 10 ថ្ងៃផ្ទួនៗគ្នាដែលមានកំរិតលើការបញ្ឈប់បណ្តោះអាសន្ន ឬ 20 ថ្ងៃសរុបដែលមានកំរិតក្នុងឆ្នាំសិក្សា ។

នៅក្នុងករណីខ្លះ, ការបបញ្ឈប់បណ្តោះអាសន្នជាច្រើនលើកដែលបូកបញ្ចូលទៅលើសពី 10 ថ្ងៃសិក្សាក្នុងឆ្នាំសិក្សាប្រហែលជារួមគ្នាជាផ្លាស់ប្តូរទីកន្លែងសិក្សាដោយមិនចាំមានការប្រជុំ IEP ឡើយ ហើយនិងសេចក្តីយល់ព្រមពីមាតាបិតា បើសិនជាការបញ្ឈប់បណ្តោះអាសន្ននៅជាគំរូបញ្ចាំងបង្ហាញនៃអកប្បកិរិយាមិនគប្បី ។ កត្តាដូចជារយៈពេលដកចេញម្តង, ចំនួនសរុបពេលវេលានៃការដកសិស្សចេញ, ភាពជិតដល់នៃការដកចេញមួយណាផ្សេងទៀត, ហើយនិងភិនភាគប្រហាក់ប្រហែលនៃអកប្បកិរិយាលើការបញ្ឈប់បណ្តោះអាសន្នជាច្រើនលើកប្រហែលជាយកមកគិតគូក្នុងការសម្រេចមើលបើគំរូនៃការបញ្ឈប់បណ្តោះអាសន្នទំនងមកពីការផ្លាស់ប្តូរទីកន្លែង ឬការបណ្តេញចេញខុសច្បាប់ ។ បើសិនជាការបញ្ឈប់បណ្តោះអាសន្នជាគំរូ, ដូច្នេះការបញ្ឈប់បណ្តោះអាសន្នជាច្រើនលើករួមគ្នាជាការផ្លាស់ប្តូរទីកន្លែង ។ [11] បើសិនជាការបញ្ឈប់បណ្តោះអាសន្នអាចយកមកគិតការផ្លាស់ប្តូរទីកន្លែងសិក្សា, បន្ទាប់មកក្រុម IEP ត្រូវតែមានការប្រជុំកំណត់ជាក់ស្តែង ហើយសិទ្ធិនិងកាតព្វកិច្ចទាក់ទងទៅនិងការផ្លាស់ប្តូររាប់បញ្ចូល ។ [12]

ឧទាហរណ៍, បើសិនជាកូនលោកអ្នកបានទទួលការបញ្ឈប់បណ្តោះអាសន្នបូកសរុបទៅមានចំនួន 12 ថ្ងៃសិក្សា ហើយឆ្នាំសិក្សាទើបតែឈានចូលបានពាក់កណ្តាលឆ្នាំ, លោកអ្នកប្រហែលជាអាចបង្កើតការជិតក្នុងពេលវេលានៃការបញ្ឈប់បណ្តោះអាសន្នទាំងអស់ដូចជាតំណាងនៃគំរូបញ្ចាំង ។ បន្ថែមទៅទៀត, បើសិនជាការបញ្ឈប់បណ្តោះអាសន្ន ទាំងអស់ដោយសារឧប្បត្តិហេតុអកប្បកិរិយាមិនគប្បីស្រដៀងគ្នា ឬមានប្រភេទអកប្បកិរិយាស្រដៀងគ្នាណាស់, លោកអ្នកប្រហែលក៏អាចតវ៉ាថាគំរូបញ្ចាំងនោះមានវត្តមាន ។ ចំពោះមូលហេតុទាំងនេះ, ការបញ្ឈប់បណ្តោះរបស់កូនលោកអ្នកប្រហែលជាអាចយកមកគិតផ្លាស់ប្តូរទីកន្លែងដោយមិនចាំមានការប្រជុំ IEP ឬការយល់ព្រមពីមាតាបិតា ។ ក្នុងឧទាហរណ៍នេះ, បើសិនការបញ្ឈប់បណ្តោះអាសន្នសរុបមាន 12 ថ្ងៃសិក្សានៃដកហូតនោះប្រហែលជាអាចយកមកគិតផ្លាស់ប្តូរនៃទីកន្លែង, បន្ទាប់មកមានការការ

ពារបន្ថែមតាមច្បាប់សំរាប់សិស្សទាំងឡាយដែលមានភាពពិការដែលគេកំពុងតែគិតគូ បណ្តេញចេញប្រហែលជាអាចរាប់បញ្ចូលបាន ។

ផ្នែកទី 8 នៃក្បួនរបស់ភ្នាក់ងារ PAI *ស្តីពីសិទ្ធិអប់រំពិសេសនិងបន្ទុក (Special Education Rights and Responsibilities, SERR)* មានពិភាក្សាពីការបញ្ឈប់បណ្តោះអាសន្ននិងការបណ្តេញចេញបានក្បោះក្បាយ ។ ក៏សូមអានព្រឹត្តិប័ត្ររបស់ភ្នាក់ងារ PAI ពីការបណ្តេញចេញ, មានចំណងជើង *YIKES! កូនពិការរបស់ខ្ញុំ គេកំពុងតែយកមកពិនិត្យដើម្បីបណ្តេញចេញ !*

## *B. ការធ្វើអន្តរាគមន៍ពីអកប្បកិរិយាល្អ*

បើសិនជាកូនលោកអ្នកមានអកប្បកិរិយាដែលបង្អាក់ ឬប៉ះពាល់រំខានដល់ការរៀនសូត្ររបស់វា ឬដល់អ្នកដទៃ, កូននោះមានសិទ្ធិទទួលកិច្ចបំរើទាក់ទងនិងជំនួយជួយជំនួសផ្សេងៗទៀត ហើយនិងកិច្ចបំរើIEPផ្សេងៗដែលប្រហែលជាចាំបាច់ចំពោះកូនលោកអ្នកដើម្បីទទួលផលប្រយោជន៍ពីកម្មវិធីអប់រំពិសេសរបស់វា ។ [13] ច្បាប់អប់រំពិសេសតម្រូវឲ្យក្រុម IEP ត្រូវធ្វើ, នៅពេលសមរម្យ, គិតរកមធ្យោបាយ, រួមទាំងការស្ទង់ប៉ាន់មើល[14], ធ្វើអន្តរាគមន៍ពីអកប្បកិរិយាល្អ និងការគាំទ្រ[15], ដើម្បីធ្វើការអធិប្បាយពីអកប្បកិរិយា ។

បន្ថែមទៅទៀត, រដ្ឋកាលីហ្វ័រនីញ៉ាមានច្បាប់សំរាប់ធ្វើអន្តរាគមន៍ពីអកប្បកិរិយាពិសេស, ជួនកាលហៅថា “Hughes Bill Behavioral Interventions” (“ច្បាប់ Hughes ធ្វើអន្តរាគមន៍ពីអកប្បកិរិយា”) ។ ច្បាប់ពិសេសទាំងអស់នេះ តម្រូវឲ្យមានការស្ទង់ប៉ាន់មើលដ៏ធំទូលាយនិងក្បោះក្បាយដែលហៅថា “Functional Analysis Assessment (FAA)” (ដំណើរវិភាគស្ទង់ប៉ាន់មើល) ឬ “Hughes Bill Assessment” (ច្បាប់ Hughes ស្ទង់ប៉ាន់មើល) និងការរីកចំរើនហើយនិងការអនុវត្តន៍នៃគំរោងអន្តរាគមន៍ពីអកប្បកិរិយាល្អ ។ ច្បាប់ទាំងនេះក៏ហាមខាត់ការប្រើអន្តរាគមន៍ពីអកប្បកិរិយាដែលប្រឆាំងផងដែរ ។ [16]

ក្រុម FAA រកឃើញ, ពត៌មាននិងអនុសាសន៍ដែលបន្ទាប់មកបានប្រើក្នុងការបង្កើតគំរោងធ្វើអន្តរាគមន៍ពីអកប្បកិរិយាល្អសំរាប់ឲ្យសិស្ស ។ គំរោងនោះក្លាយជាផ្នែកមួយនៃការធ្វើ IEP របស់សិស្ស ហើយគំរោងនោះមានគោលដៅរបស់ខ្លួន ហើយនិងទិសដៅទាក់ទងទៅនិងការកាត់បន្ថយលើការមិនចុះសម្រុងនិងអ្វីមួយ ឬអកប្បកិរិយាមិនពេញចិត្ត និងជំនួសមូលហេតុទាំងនោះជាមួយនិងអ្វីដែលទទួលយកបាន ហើយនិងអកប្បកិរិយាសមរម្យជាងនេះ ។ ម្យ៉ាងទៀត, គំរោងធ្វើអន្តរាគមន៍ពីអកប្បកិរិយាអាចតែយកមកអនុវត្តបានតែប៉ុណ្ណោះដោយ ឬត្រួតពិនិត្យមើលដោយអ្នកណាម្នាក់ដែលមានការហ្វឹកហ្វឺនជាក់លាក់ក្នុងការធ្វើវិភាគអកប្បកិរិយា ។ [17]

បើសិនជាសិស្សបង្ហាញនូវអកប្បកិរិយាមិនអាចទាយទុកមុនបានជាឯកឯងដែលទំនងបង្ហាញនូវភាពគ្រោះថ្នាក់ច្បាស់លាស់ដល់ខ្លួនប្រាណរបស់វាផ្ទាល់ ឬអ្នកដទៃ, បុគ្គលិកសាលារៀនប្រហែលជាប្រើការធ្វើអន្តរាគមន៍ពេលមានភាពអាសន្ន ។ ក៏ប៉ុន្តែការធ្វើអន្តរាគមន៍ពេលមានភាពអាសន្នមិនអាចយកប្រើប្រាស់យូរជាងពេលវេលាដែលចាំបាច់ត្រូវការដើម្បីទប់ខត់ ឬទប់កំហឹងអកប្បកិរិយាបានឡើយ ។ [18] ម្យ៉ាងទៀត, គំរោងធ្វើអន្តរាគមន៍ពីអកប្បកិរិយា *មិនគួរ* ត្រូវបានយកមកប្រើក្នុងតួនាទីឲ្យមានរបៀបគំរោងធ្វើអន្តរាគមន៍ពីអកប្បកិរិយារៀបចំដើម្បីផ្លាស់ប្តូរ, ផ្លាស់ ឬធ្វើឲ្យបានប្រសើរឡើងជាងមុននូវអកប្បកិរិយាដែលគិតនោះ ។ [19]

ផ្នែកទី 5 នៃក្បួន *SERR* របស់ភ្នាក់ងារ PAI មានពិភាក្សាពីកិច្ចបំរើទាក់ទង, ការធ្វើអន្តរាគមន៍ការពារអកប្បកិរិយា, ធ្វើអន្តរាគមន៍ការពារភាពមានអាសន្ន ហើយនិងធ្វើអន្តរាគមន៍ការពារអកប្បកិរិយាហាមខត់ក្បោះក្បាយ ។ ក៏សូមអានតារាងបង្ហាញការធ្វើអន្តរាគមន៍ការពារអកប្បកិរិយានៅចុងផ្នែកទី 5 នេះ ។

## *C. បរិវេណដែលមានកំរិតលក្ខខ័ណ្ឌតិច និងទីកន្លែងរៀនសូត្រ*

Least Restrictive Environment (បរិវេណមានកំរិតលក្ខខ័ណ្ឌតិច, LRE) គឺជាតម្រូវការក្នុងច្បាប់អប់រំពិសេសដែលក្មេងមានភាពពិការទទួលការអប់រំរបស់គេ,

ដល់ការវិសាលភាពខ្ពស់សមរម្យបំផុត, ជាមួយសិស្សមិនពិការផ្សេងៗទៀត ។ ការអប់រំពិសេសក៏តម្រូវឲ្យតំបន់អប់រំមើលពីសិស្សទទួលការអប់រំពិសេសនីមួយៗអាចអប់រំបានពេញចិត្តក្នុងបន្ទប់បង្រៀនធម្មតាដោយមានឧបករណ៍ជំនួយជួយ ហើយនិងកិច្ចបំរើផ្សេងៗមុនពេលគិតដាក់បរិវេណមានកំរិតលក្ខខ័ណ្ឌបន្ថែមណាមួយទៀត ។ [20] នេះមានន័យថាសិស្សទទួលការអប់រំពិសេសមិនគួរបានដកចេញពីថ្នាក់អប់រំធម្មតាលុះណា, សូម្បីតែមានកិច្ចបំរើផ្សេងៗទៀតជួយដល់សិស្សក៏ដោយ, សិស្សមិនអាចសិក្សាបានរីកចំរើន ឬទទួលផលប្រយោជន៍ពីថ្នាក់រៀនធម្មតាទាំងឡាយនោះបាន ។

ក្រោមតម្រូវការ LRE, ក្រុម IEP ត្រូវតែគត់ចុះសនិទានភាពរបស់វាសំរាប់ធ្វើអនុសាសពីទីកន្លែងឲ្យរៀនសូត្រដែលខុសប្លែកពីសាលារៀន និងថ្នាក់រៀនដែលសិស្សប្រហែលជាអាចមករៀន បើសិនជាសិស្សនោះមិនមែនពិការទេនោះ ។ ឯកសារគត់ទុកក៏គួរតែមានបញ្ជាក់នូវមូលហេតុពីភាពពិការរបស់សិស្សដែលរារាំងលើសេចក្តីត្រូវការរបស់វានៃការសិក្សាស័ក្តិសមក្នុងបរិវេណមានកំរិតលក្ខខ័ណ្ឌតិច សូម្បីតែមានប្រើឧបករណ៍ជំនួយ និងកិច្ចបំរើទាំងឡាយ ។ នេះមានន័យថា *មុននិងធ្វើ*អនុសាសដាក់សិស្សក្នុងទីកន្លែងមានបញ្ហាអកប្បកិរិយាធ្ងន់ធ្ងរ ឬទីកន្លែងពិការផ្សេងៗទៀតដែលដាច់ដោយឡែក, ដូចជាថ្នាក់បង្រៀនពិសេស ឬសាលារៀនមិនមែនជាសាធារណៈ ឬដាក់ឲ្យរៀនសូត្រនៅផ្ទះផ្ទាល់, ក្រុម IEP គួរតែគិតមើល, ផ្តល់ឲ្យ, បង្កើត ហើយ/ឬអនុវត្តកិច្ចបំរើជួយគាំទ្រដូចជាការប្រដៅណែនាំ, កិច្ចបំរើ AB3632 [21], ជំនួយផ្នែកអកប្បកិរិយាមួយ-ទល់-មួយផ្ទាល់, គំរោងធ្វើអន្តរាគមន៍ពីអកប្បកិរិយា, ដំណើរវិភាគស្ទង់ប៉ាន់មើល ហើយនិងកិច្ចបំរើទាក់ទងផ្សេងៗទៀត ។

ម្យ៉ាងវិញទៀត, ចំណងជើង 2 California Code of Regulations (ខ្ទង់នៃច្បាប់កាលីហ្វ័រនីញ៉ា), § 60100 ផ្តល់ឲ្យនូវ :

> មុនពេលកំណត់គិតដាក់សិស្សរៀនសូត្រនៅផ្ទះផ្ទាល់ គឺជាការចាំបាច់ចំពោះសិស្សដែលទទួលការអប់រំពិសេស ហើយនិងកិច្ចបំរើភ្នែកវិបត្តិផ្លូវចិត្ត, ក្រុមពង្រឹង IEP គួរតែគិតពីទីកន្លែងដាក់ជំនួសដែលមានកំរិតលក្ខខ័ណ្ឌតិច ដូចជាការផ្តល់ឲ្យមានអ្នកឯកទេសខាង

អកប្បកិរិយា ហើយនិងអ្នកជំនួយខាងអកប្បកិរិយាពេញថ្ងៃនៅក្នុងថ្នាក់រៀន, នៅផ្ទះ, ហើយនិងនៅក្នុងបរិវេណសហគមន៍ ហើយ/ឬហ្វឹកហ្វឺនមាតាបិតានៅនិងផ្ទះ ហើយនិងបរិវេណសមាគមន៍ ។ ក្រុម IEP គួរតែគត់ចុះការជំនួសឯល់ការដាក់ឲ្យរៀនសូត្រនៅផ្ទះផ្ទាល់ដែលបានគិតមកហើយនោះ ហើយនិងមូលហេតុទាំងឡាយដែលបដិសេធប្រឆាំងមិនទទួលយក ។ ការជំនួសដូចនេះ ប្រហែលជារួមមានបញ្ចូលការបង្កើតការអប់រំរួមគ្នា ហើយនិងកិច្ចបំរើផ្នែកវិបត្តិផ្លូវចិត្ត ។

នៅក្នុងផ្នែកនៃ California Code of Regulations នេះសង្កត់បន្ថែម ហើយនិងការគាំទ្រ LRE ។ ផ្នែក 60100 បញ្ជាក់ថា មុនពេលធ្វើអនុសាស ឬបញ្ជូនក្មេងទៅដាក់ក្នុងកម្មវិធីអប់រំនៅផ្ទះផ្ទាល់, តំបន់អប់រំប្រហែលជាត្រូវផ្តល់ឲ្យជំនួយខាងអកប្បកិរិយាមួយ-ទល់-មួយផ្ទាល់ពេលក្រៅម៉ោងសាលារៀន ។ ដោយយោងទៅលើធម្មជាតិនៃភាពពិការរបស់ក្មេង, ក្មេងនោះប្រហែលត្រូវការជំនួយបន្ថែម ដើម្បីជួយធ្វើឲ្យវាឈប់រៀនសូត្រក្នុងកម្មវិធីអប់រំមិនមែននៅផ្ទះ, ដូចជាឲ្យមានអ្នកជំនួយជួយមួយ-ទល់-មួយផ្ទាល់នៅពេលព្រឹកព្រលឹម (ដើម្បីរៀបចំឲ្យក្មេងទៅសាលារៀន), ហើយក្រោយពេលថ្ងៃត្រង់ (ដើម្បីជួយក្មេងត្រឡប់ទៅផ្ទះវិញ) ។

***សំគាល់ :*** *បើសិនជាលោកអ្នកចង់បានផ្នែកផ្សេងៗទៀតពីក្បួន SERR ឬព្រឹត្តិប័ត្រផ្សេងៗទៀត, លោកអ្នកទាញយកពីគេហទំព័រ PAI តាមអាសយដ្ឋាន www.pai-ca.org ឬលោកអ្នកស្នើសុំបានដោយទូរស័ព្ទមកការិយាល័យរបស់យើងដោយមិនអស់លុយលេខ (800) 776-5746 ។*

## អក្សរកាត់ឯល់កន្លែងច្បាប់

| | |
|---|---|
| §, §§ | ផ្នែក, ផ្នែកច្រើន |
| 20 U.S.C. | ចំណងជើង 20 ខូដនៃសហរដ្ឋអាមេរិក (United States Code) |
| 34 C.F.R. | ចំណងជើង 34 ខូដនៃច្បាប់សហពន្ធ (Code of Federal Regulations) |
| Cal. Ed. Code | ខូដអប់រំរដ្ឋកាលីហ្វ័រនីញ៉ា (California Code of Regulations) |
| 5 C.C.R. | ចំណងជើង 5 ខូដនៃច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា (California Code of Regulations) |

## កត់សំគាល់ខាងចុង

[1] 20 U.S.C. § 1415(k); Cal. Ed. Code § 48900.5, 48911.5; ចូរមើលច្បាប់បញ្ឈប់បណ្ដោះអាសន្នទូទៅ, Cal. Ed. Code §§ 48900 – 48915.5

[2] Cal. Ed. Code § 48903

[3] 34 C.F.R. § 300.530(b)

[4] 34 C.F.R. § 300.530(e); ចូរមើលព្រឹត្តិប័ត្ររបស់ភ្នាក់ងារ PAI: *YIKES! កូនពិការរបស់ខ្ញុំគេកំពុងតែយកមកពិនិត្យដើម្បីបណ្ដេញចេញ !*

[5] 34 C.F.R. § 300.530(b)

[6] 34 C.F.R. § 300.530(b)

[7] 34 C.F.R. §§ 300.530(b)(2) និង (d)(4); និង 300.536

[8] 20 U.S.C § 1415 (k)(1)(D); 34 C.F.R. §§ 300.530(b)(2) និង (d)

[9] 34 C.F.R. § 300.530(e); ចូរមើលព្រឹត្តិប័ត្ររបស់ភ្នាក់ងារ PAI: *YIKES! កូនពិការរបស់ខ្ញុំគេកំពុងតែយកមកពិនិត្យដើម្បីបណ្ដេញចេញ !*

[10] Cal. Educ. Code § 48903

[11] 34 C.F.R. § 300.536(a)(2)

[12] 34 C.F.R. § 300.530(e); ចូរមើលព្រឹត្តិប័ត្ររបស់ភ្នាក់ងារ PAI: *YIKES! កូនពិការរបស់ខ្ញុំគេកំពុងតែយកមកពិនិត្យដើម្បីបណ្ដេញចេញ !*

[13] 20 U.S.C §1401(26) និង (33); 34 C.F.R. § 300.34; Cal. Ed. Code §§ 56033.5, 56520 – 56525, 56363; និង 5 Cal. Code Regs. §§ 3001 (d), (e) និង (f), 3052

[14] 34 C.F.R. § 300.304(b)(4); Cal. Ed. Code § 56320(f); *ចូរមើល :* ទម្រង់សួង់ប៉ាន់មើល, វាយតម្លៃ និងការវាយតម្លៃជាថ្មីម្តងទៀត 34 C.F.R. §§ 300.303 – 300.305

[15] Cal. Ed. Code §§ 56520, 56521 និង 56523

[16] Cal. Ed. Code §§ 56520 – 56525; 5 Cal. Code Regs. §§ 3001 (d), (e) និង (f), និង 3052

[17] Cal. Ed. Code §§ 56520 – 56525; 5 Cal. Code Regs. §§ 3001 (d), (e) និង (f), និង 3052

[18] 5 C.C.R. § 3052(i)(3)

[19] 5 C.C.R. § 3052(i)(1)

[20] 20 U.S.C. § 1412(a)(5); 34 C.F.R. § 300.114; Cal. Ed. Code § 56031, 56342

[21] ច្បាប់ AB3632 តម្រូវឲ្យតំបន់អប់រំបង្កើតការយល់ព្រមជាមួយភ្នាក់ងារដែលមិនមែន ជាភ្នាក់ងារអប់រំ, ដូចជាមន្ទីរខោនធីសុខាជម្ងឺវិបត្តិផ្លូវចិត្ត (County Departments of Mental Health, “CMH”) ដើម្បីផ្តល់ឲ្យកិច្ចបំរើផ្សេងៗ ដូចជាការប្រដៅណែនាំ, ការព្យាបាលចិត្តរោគ ដោយមិនប្រើថ្នាំ ឬការព្យាបាលក្រុមគ្រួសារដោយមិនប្រើថ្នាំ ។ បើសិនជាមានបញ្ជូនសិស្ស ទៅមន្ទីរ CMH ក្រោមច្បាប់ AB3632 ហើយគេបានគិតថាការសួង់ប៉ាន់មើលជាការចាំបាច់, ក្នុងករណីជាច្រើន, មន្ទីរ CMH មានរយៈពេល 60 ថ្ងៃដើម្បីបំពេញការសួង់ប៉ាន់មើល ក្រោយពីបានទទួលសេចក្តីយល់ព្រមពីមាតាបិតាជាលាយលក្ខណ៍អក្សរ ។ កិច្ចបំរើទាំង ឡាយដែលផ្តល់អោយក្រោមច្បាប់ AB3632, ក៏ដូចជាកិច្ចបំរើទាំងឡាយទាក់ទិនដែរ, គួរតែសរសេរដាក់បញ្ចូលក្នុង IEP ។ មានពត៌មានបន្ថែមពីកិច្ចបំរើទាំងឡាយក្រោមច្បាប់ AB3632 អាចរកមើលមាននៅក្នុងផ្នែកទី 9 នៃក្បួនរបស់ភ្នាក់ងារ PAI, *សិទ្ធិអប់រំពិសេសនិងបន្ទុក (Special Education Rights and Responsibilities)* ។ Gov. Code §§ 7570, *ជាលំដាប់*; 2 Cal. Code Regs. §§ 60000, *ជាលំដាប់*